វិទ្យាល័យ ISSR
ព្រឹត្តិការណ៍ប្រចាំសប្តាហ៍
ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២


# ISSR HIGH SCHOOL NEWSLETTER

ISSUE | 06 | SEPTEMBER | 2022





















## កម្មវិធីទទួលស្វាគមន៍ អាណាព្យាបាលសិស្សានុសិស្ស ផ្នែកវិទ្យាល័យ ២០២២-២០២៣

នាល្ងាចថ្ងៃសុក្រ ទី០២ ខែកញ្ញា ឆ្នាំ២០២២ សាលាអន្តរជាតិ ISSR ផ្នែកវិទ្យាល័យ បានរៀបចំកម្មវិធីទទួលស្វាគមន៍អាណាព្យាបាលសិស្សានុសិស្ស សម្រាប់ឆ្នាំសិក្សា២០២២-២០២៣។ កម្មវិធីនេះជាទូទៅរៀបចំឡើងនៅរៀងរាល់ដើមឆ្នាំសិក្សានីមួយៗ ដើម្បីផ្តល់ឱកាសជូនលោក លោកស្រីដែលជាមាតា បិតា ឬអ្នកអាណាព្យាបាលសិស្សានុសិស្សបានជួបសំណេះសំណាល ស្វែងយល់អំពីការបង្រៀន និងរៀនរបស់កូនៗ។ ក្នុងកម្មវិធីនេះផងដែរ គណៈគ្រប់គ្រងផ្នែកខេមរភាសានិងផ្នែកអន្តរជាតិបានរាយការណ៍ជូនអំពីវឌ្ឍនៈភាពទូទៅរបស់សាលា និងបានណែនាំពីសមាសភាពគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូទាំងអស់ដែលបម្រើការងារនៅសាលាអន្តរជាតិ ISSR។

ជាកិច្ចបញ្ចប់នៃកម្មវិធី គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ បុគ្គលិកសាលា ព្រមទាំងអាណាព្យាបាលទាំងអស់ដែលមានវត្តមានក្នុងពិធី បានចូលរួមពិសាអាហារសាមគ្គីរួមគ្នា។ ហើយកម្មវិធីទទួលស្វាគមន៍អាណាព្យាបាល សិស្សានុសិស្ស ផ្នែកវិទ្យាល័យបានបញ្ចប់ទៅដោយជោគជ័យ ក្រោមបរិយាកាសរីករាយ និងកក់ក្តៅគួរឱ្យចងចាំ។

សាលាអន្តរជាតិ ISSR សូមថ្លែងអំណរគុណចំពោះលោក លោកស្រីដែលជាមាតា បិតា ឬអ្នកអាណាព្យាបាលដែលបានចំណាយពេល វេលាដ៏មានតម្លៃ អញ្ជើញមកចូលរួមកម្មវិធីរបស់សាលា ហើយក៏សូមអរគុណចំពោះការចូលរួមជាមតិដើម្បីជួយជ្រោមជ្រែងដល់ការបង្រៀន និងរៀនរបស់សិស្សានុសិស្សទាំងអស់គ្នាផងដែរ។



## High School Parent Meet and Greet 2022-2023

On Friday September 2nd, 2022, ISSR High School hosted its annual event to welcome parents and guardians to the new academic year 2022-2023. We do this to cement connections between parents and teachers and allow an opportunity for parents to gain information regarding their child's learning. In addition, the ISSR management team shared the improvements we have made in school and provided important reminders to parents and guests regarding future events that we have planned.

The High School parent meet and greet ended with a buffet when parents chatted with staff about the school, their students and the school's aims and overall ethos.
It was a memorable evening for everyone after a year in which the pandemic had made this kind of interaction problematic, if not impossible.

We wish to allow parents every opportunity to interact with staff, offer their views and gain information about their students, so we feel this event was the perfect occasion to restart this conversation.